ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

terre des hommes
stops child exploitation

# កិច្ចព្រមព្រៀង

## រវាង

## គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស គ.ជ.ប.ជ

## និង

## អង្គការ ដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា

## ស្តីពី

## ការចូលរួមសកម្មភាពប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស នៅព្រះរាជាណាចក្រកម្ពុជា

**ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

# ផ្នែកទី១
## បុព្វកថា

**ដោយហេតុថា**

- រាជរដ្ឋាភិបាលកម្ពុជា មានការប្តេជ្ញាចិត្តខ្ពស់ និងទទួលអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង និងពិធីសារ(បំពេញបន្ថែម)ស្តីពីការទប់ស្កាត់ ការបង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ។
- គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលក្នុងកិច្ចព្រមព្រៀងនេះ ហៅកាត់ថា គ.ជ.ប.ជ គឺជាយន្តការអន្តរស្ថាប័នរបស់ជាតិដែលមានតួនាទីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំ សម្របសម្រួលប្រមូលផ្តុំការចូលរួមកិច្ចសហការ និងការគាំទ្រពីក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការសហប្រជាជាតិ អង្គការដៃគូជាតិ អន្តរជាតិ ផ្នែកឯកជនរួមទាំងយន្តការក្នុងតំបន់ និងបណ្តាប្រទេសពាក់ព័ន្ធទាំងឡាយ សម្រាប់ការងារប្រយុទ្ធប្រឆាំងនឹងរាល់ទម្រង់នៃអំពើជួញដូរ និងអំពើធ្វើអាជីវកម្មកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាព ជាពិសេសលើស្ត្រីនិងកុមារ ដែលកើតមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងលើពលរដ្ឋកម្ពុជា នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។
- គ.ជ.ប.ជ មានវិសាលភាពទូលំទូលាយ តាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ និងបើកទូលាយសម្រាប់កិច្ចសហការជាមួយក្រសួង ស្ថាប័នជាតិ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដើម្បីធ្វើឲ្យសម្រេចគោលដៅរួមនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- គ.ជ.ប.ជ មានភារកិច្ចសម្របសម្រួល ពង្រឹងកិច្ចសហការទ្វេភាគី ពហុភាគីជាមួយគ្រប់ភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិប្រមូលផ្តុំគ្រប់កិច្ចខិតខំប្រឹងប្រែងទាំងឡាយ ដែលបម្រើឲ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលរួមមានការអនុវត្តច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ និងអន្តរជាតិ ព្រមទាំងជម្រុញការអនុវត្តសកម្មភាពទាំងឡាយដែលបានគ្រោងទុក ។
- គ.ជ.ប.ជ មានភារកិច្ច អប់រំផ្សព្វផ្សាយ បណ្តុះបណ្តាលពង្រឹងសមត្ថភាពអ្នកអនុវត្តគ្រប់ផ្នែកគ្រប់កម្រិត ដើម្បីបង្ការទប់ស្កាត់បទល្មើសជួញដូរមនុស្ស និងភាពរងគ្រោះរបស់ប្រជាពលរដ្ឋដោយអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយដែលជ្រកក្រោមរូបភាពផ្សេងៗ (ជាពិសេស រូបភាពជាទេសន្តរប្រវេសន៍ ការស្វែងរកការងារ និងដៃគូអាពាហ៍ពិពាហ៍ជាមួយជនបរទេស សេវាកំសាន្តពេស្យាកម្ម ។ល។) ការជួយសង្គ្រោះ ការថែទាំ ការការពារ និងការអភិវឌ្ឍន៍ជនរងគ្រោះ ការអនុវត្តច្បាប់ ដោយការបង្ក្រាប និងការផ្តន្ទាទោស ជនល្មើស ។
- គ.ជ.ប.ជ មានភារកិច្ច តាមដាន ត្រួតពិនិត្យ វាយតម្លៃអំពីប្រសិទ្ធភាព និងសភាពការណ៍ប្រែប្រួល ស្រាវជ្រាវប្រមូលពត៌មាន ពាក់ព័ន្ធនឹង មូលហេតុ ផលប៉ះពាល់ និងល្បិចកល នៃបទល្មើស

ជួញដូរមនុស្ស ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រ និងសកម្មភាពនៃផែនការ និងឈានទៅបង្កើតគំនិតផ្តួចផ្តើមទាំងឡាយដែលមានប្រយោជន៍សម្រាប់បម្រើឲ្យគោលដៅប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

**ដោយយល់ឃើញថា**

- អង្គការដែនដីមនុស្សហ្វូឡង់ដ៏ ប្រចាំកម្ពុជា ជាអង្គការអន្តរជាតិ/ជាតិ ដែលមានការទទួលស្គាល់ពីរាជរដ្ឋាភិបាល មានទស្សនៈវិស័យ គោលដៅ គោលបំណង ស្របគ្នាទៅនឹងរាជរដ្ឋាភិបាលកម្ពុជា និងមានធនធានគ្រប់គ្រាន់សម្រាប់អនុវត្តភារកិច្ចតាមការគ្រោងទុក ។
- អង្គការដែនដីមនុស្សហ្វូឡង់ដ៏ ប្រចាំកម្ពុជា មានឆន្ទៈចូលរួម គាំទ្រ និងសហការជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល តាមរយៈគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងសកម្មភាពមួយចំនួនដែលរួមចំណែកដល់ការធ្វើឲ្យសម្រេច ផែនការជាតិ ០៥ ឆ្នាំ ២០១៤- ២០១៨ របស់ គ.ជ.ប.ជ ។
- អង្គការដែនដីមនុស្សហ្វូឡង់ដ៏-ប្រចាំកម្ពុជា ធ្លាប់បានធ្វើសកម្មភាពនៅកម្ពុជា តាំងពីឆ្នាំ២០០៧ មានប្រវត្តិការងារល្អ ក្នុងការធ្វើសកម្មភាពមនុស្សធម៌ អព្យាក្រឹត្យ មិនលំអៀងដោយទស្សនៈនយោបាយ និងមានសហការល្អជាមួយរាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូអន្តរជាតិ និងសង្គមស៊ីវិលដទៃទៀត ។

**ហេតុនេះ ភាគទាំងពីរ** ដែលមានៈ

១. គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ និងទទួលអនុវត្តផ្ទាល់ ជា **ភាគ ក** តំណាងដោយៈ

**លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។

២. អង្គការដែនដីមនុស្សហ្វូឡង់ដ៏-ប្រចាំកម្ពុជា ជា **ភាគ ខ** តំណាងដោយៈ

**លោក សួន សុភាព** ប្រធានគ្រប់គ្រងប្រចាំប្រទេសកម្ពុជា។

បានឯកភាពគ្នា ចុះហត្ថលេខាលើ **កិច្ចព្រមព្រៀង ស្តីពីការចូលរួមប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** នៅលើចំណុចមួយចំនួន ដែលបានរៀបរាប់ដូចខាងក្រោមៈ

# ផ្នែកទី២
## គោលបំណងនៃកិច្ចព្រមព្រៀង

**ប្រការ ១.** គោលបំណងទូទៅនៃកិច្ចព្រមព្រៀងនេះ គឺធ្វើឡើង ក្នុងគោលបំណងពង្រឹងកិច្ចសហការ រវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និង អង្គការដែនដីមនុស្សហូឡង់ដ៍ ប្រចាំកម្ពុជា ដើម្បីលើកកំពស់ការអនុវត្តន៍ច្បាប់ និងគោលនយោបាយជាតិ យុទ្ធសាស្ត្រនៃផែនការសកម្មភាព ជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ ២០១៥-២០១៨ សំដៅរក្សាសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរបស់ មនុស្ស ឲ្យទទួលបាននូវការគោរពសិទ្ធិពេញលេញ និងជៀសផុតពីអំពើជួញដូរ និងអំពើកេងប្រវ័ញ្ចលើ មនុស្សគ្រប់រូបភាពដោយមិនរើសអើង ។

**ប្រការ ២.** គោលបំណងរបស់អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជា គឺផ្តោតការយកចិត្តទុកដាក់លើ ការការពារកុមារ ការបង្ការទប់ស្កាត់ ការផ្តល់សេវាថែទាំ ការផ្សព្វផ្សាយ និងការអនុវត្តន៍ច្បាប់ដើម្បីលុបបំបាត់ រាល់ការកេងប្រវ័ញ្ចលើកុមារ។

- អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជា បាននឹងកំពុងអនុវត្តសកម្មភាពតាមរយៈអង្គការដៃគូ ចំនួន៨នៅក្នុងប្រទេសកម្ពុជារួមមាន៖ អង្គការសកម្មភាពដើម្បីកុមារ(Action Pour Les Enfants) អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(Cambodian Women's Crisis Center) សម្ព័ន្ធអង្គការមិនមែន រដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា(Cambodia Against Child Trafficking) អង្គការ សន្តិសេនា(Santi Sena Organization) អង្គការកុមារនៃក្តីសង្ឃឹម(Kumar Ney Kdey Sangkheum) អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា(Child Helpline Cambodia) អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ (Cambodian Organization for Children and Development) និងសមាគមកុមារ និងជីវិត(Children and Life Association)។ អង្គការទាំងអស់នោះកំពុងអនុវត្តគម្រោងនៅតាមបណ្តា ខេត្តមួយចំនួនដូចជា៖ ក្រុងភ្នំពេញ ខេត្តពោធិសាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្ត សៀមរាប ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តតាកែវ និងខេត្តមួយ ចំនួនទៀត។

# ផ្នែកទី ៣
## លក្ខខណ្ឌទូទៅនៃកិច្ចព្រមព្រៀង

**ប្រការ ៣.** រាល់សកម្មភាព នៃកិច្ចសហប្រតិបត្តិការ លើគម្រោងនានា (ឧទាហរណ៍ ពាក់ព័ន្ធនឹងចំណាក ស្រុកដោយសុវត្ថិភាព ដើម្បីកាត់បន្ថយការជួញដូរមនុស្សជាពិសេសកុមារ ឬការបង្ការទប់ស្កាត់ ឬការជួយជន

រងគ្រោះតាមរយៈការផ្តល់សេវាសង្គម សេវាផ្នែកច្បាប់ ។ល។) ត្រូវមានការឯកភាពពីភាគីទាំងពីរ ឬអាចរួមសហការជាមួយដៃគូដទៃទៀតដោយមានការដឹងឮពីភាគីទាំងពីរ ។

**ប្រការ ៤.** ភាគីទាំងពីរ ឯកភាពចាត់មន្ត្រី ឬតំណាង ដើម្បីទំនាក់ទំនងការងារឲ្យបានជិតស្និទ្ធ និង ចូលរួមពិនិត្យដំណើរការសកម្មភាព និង សមិទ្ធិផលនានា និងធ្វើការវាយតម្លៃ ដោយភាគីទាំងពីរ ។

**ប្រការ ៥.** ភាគីទាំងពីរឯកភាពគ្នា ផ្តល់ការគាំទ្រ ដល់ការពង្រឹងសមត្ថភាពបុគ្គលិក របស់គម្រោង និង អង្គការដៃគូររបស់ភាគី អាជ្ញាធរមូលដ្ឋាន និង សមត្ថកិច្ចពាក់ព័ន្ធ ក្នុងតំបន់គោលដៅ សំដៅរួមសហការគ្នាឲ្យបានល្អប្រសើរ ។

**ប្រការ ៦.** ភាគីទាំងពីរ ឯកភាពគ្នា ធ្វើការតាមដាន វាយតម្លៃប្រសិទ្ធភាពនៃគម្រោងសកម្មភាព រួមគ្នា និងផ្លាស់ប្តូរយោបល់គ្នាដោយតម្លាភាព ។

## ផ្នែកទី៤

## ភារកិច្ច និងការទទួលខុសត្រូវ របស់ភាគនៃកិច្ចព្រមព្រៀង

**ប្រការ ៧.** ភារកិច្ច និងការទទួលខុសត្រូវ របស់ **ភាគ ក**

- **ភាគ ក** មានភារកិច្ច ផ្តល់កិច្ចសហការ និងសម្របសម្រួលផ្នែករដ្ឋបាល សម្រាប់សម្រួលដល់ការអនុវត្តសកម្មភាពរបស់ **ភាគ ខ** នៅតាមបណ្តាថ្នាក់ នៃរចនាសម្ព័ន្ធគណៈកម្មាធិការជាតិ។
- **ភាគ ក** ចាត់តាំងមន្ត្រីចូលរួម និងសហការ ជាមួយ **ភាគ ខ** ក្នុងការរៀបចំកិច្ចប្រជុំ វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ការផ្តល់មតិយោបល់នានា ដែលពាក់ព័ន្ធ។
- **ភាគ ក** និង**ភាគ ខ** សហការ ផ្លាស់ប្តូរយោបល់ បទពិសោធន៍ ព័ត៌មាន សំខាន់ៗ ទៅវិញ ទៅមក តាមការចាំបាច់ ដែលពាក់ព័ន្ធនឹងភារកិច្ចនៃគូភាគី។
- **ភាគ ក** ទទួលយក និងដាក់បញ្ចូល អង្គការដៃគូរ របស់ **ភាគ ខ** ទៅក្នុងកិច្ចពិគ្រោះយោបល់ និងការធ្វើសកម្មភាព នៅតាមកម្រិត និងគោលដៅ ដែល **ភាគ ខ** ស្នើសុំ ដើម្បីរៀបចំឯកសារ។
- **ភាគ ក** យល់ព្រមទទួលការគាំទ្រជាធនធានថវិកា បច្ចេកទេស មធ្យោបាយ សម្ភារៈ ពី **ភាគ ខ** តាមការព្រមព្រៀង ដោយឥតលក្ខខណ្ឌ សម្រាប់បម្រើឲ្យការបំពេញភារកិច្ច ក្នុងទិសដៅធ្វើឲ្យសម្រេចគោលដៅរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- **ភាគ ក** ទទួលយករបាយការណ៍ ឬសេចក្តីរាយការណ៍ផ្សេងៗ ពាក់ព័ន្ធ ពី **ភាគ ខ** អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជា និងដៃគូជាទៀងទាត់ស្តីពីសកម្មភាព លទ្ធផល ភាពប្រឈម និងសំណូមពរទាំងឡាយ ដើម្បីដោះស្រាយទាន់ពេលវេលា បម្រើឲ្យប្រសិទ្ធភាពនៃការអនុវត្តន៍។

**ប្រការ ៨.** ភារកិច្ច និងការទទួកខុសត្រូវ របស់ **ភាគ ខ**

- **ភាគី ខ** យល់ព្រមផ្តល់ការគាំទ្រជាធនធានថវិកា បច្ចេកទេស មធ្យោបាយ សម្ភារៈ ដល់ **ភាគី ក** តាមការព្រមព្រៀង ដោយឥតលក្ខខណ្ឌ សម្រាប់បម្រើឲ្យការបំពេញភារកិច្ច ក្នុងទិសដៅធ្វើឲ្យសម្រេចគោលដៅរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- **ភាគី ខ** ផ្តល់ការគាំទ្រដល់ដៃគូទាំងឡាយរបស់ខ្លួន ក្នុងការធ្វើសកម្មភាពបង្ការទប់ស្កាត់ផ្តល់ការអប់រំ ជួយជនរងគ្រោះ ការផ្តល់ជំនួយផ្នែកច្បាប់ ការផ្តល់ការគាំទ្រផ្នែកជីវភាពដល់ជនរងគ្រោះ ឬជនងាយរងគ្រោះ ជាដើមដោយស្នើសុំកិច្ចសហការជាមួយគណៈកម្មាធិការជាតិ និងថ្នាក់ក្រោមជាតិអាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ ដែលត្រូវជួយសម្របសម្រួលដោយ **ភាគី ក**។
- **ភាគី ខ** ផ្តល់ព័ត៌មានត្រឡប់អំពីសកម្មភាពនិងលទ្ធផលដែលបានអនុវត្ត ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍រួមរបស់គណៈកម្មការជាតិ ។

## ផ្នែកទី៥
## អន្តរប្បញ្ញត្តិ

**ប្រការ៩.** រាល់ការកែប្រែខ្លឹមសារ និងទិសដៅនៃកិច្ចព្រមព្រៀង ឬគម្រោងសកម្មភាពនានា ដែលបានឯកភាព ត្រូវស្នើឡើងដោយភាគីសាមី និងត្រូវមានសំណើជាលាយល័ក្ខអក្សរ ឲ្យភាគីម្ខាងទៀតបានជ្រាបដើម្បីពិភាក្សារកការឯកភាពគ្នាជាថ្មី ។

**ប្រការ ១០.** កិច្ចព្រមព្រៀងនេះ ត្រូវបានបញ្ចប់តាមកាលកំណត់ ឬ ផ្អែកលើស្ថានភាពជាក់ស្តែង ណាមួយ (ដូចជា ដៃគូម្ខាងបានប្តូរទិសដៅភារកិច្ច ខ្វះធនធាន បញ្ចប់បេសកកម្ម ឬកិច្ចសហការមិនមានប្រសិទ្ធភាព មិនអនុវត្តតាមលក្ខខណ្ឌកំណត់ ..ឬជាប់ពាក់ព័ន្ធបទល្មើស..) ដែលត្រូវមានការសំរេចចិត្តរួមគ្នារវាងភាគីទាំងពីរដោយលាយលក្ខណ៍អក្សរ និងហត្ថលេខាពីភាគីតំណាងផ្លូវការទាំងពីរ ។ ភាគីទាំងពីរ អាចបន្តចុះកិច្ចព្រមព្រៀងជាថ្មី បើភាគីទាំងពីរយល់ស្របគ្នាថាចាំបាច់ ។

**ប្រការ ១១.** គណៈកម្មាធិការជាតិ គ.ជ.ប.ជ មានសិទ្ធិគ្រប់គ្រាន់ក្នុងការស្នើទៅអង្គការជា**ភាគី ខ** ដើម្បីបញ្ចប់កិច្ចព្រមព្រៀងរវាងគ្នាដោយឥតលក្ខខណ្ឌ ក្នុងករណីដែលរកឃើញថា អង្គការនេះបានជាប់ពាក់ព័ន្ធដល់សកម្មភាពដែលធ្វើអោយប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ ឬរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ឬបទល្មើសផ្សេងៗ ឬការបំពីនិន្នាការនយោបាយដែលលំអៀង និងបំផ្លាញដល់សន្តិសុខ សុវត្ថិភាពជាតិ ។

**ប្រការ ១២.** កិច្ចព្រមព្រៀងនេះ ត្រូវបានរៀបចំឡើង ជាភាសាខ្មែរ ពីរច្បាប់ និងបកប្រែ ជាភាសាអង់គ្លេស ពីរច្បាប់ ដែលច្បាប់ទាំងនេះមានតម្លៃស្មើគ្នា និងត្រូវបានចុះហត្ថលេខា ដោយតំណាងផ្លូវការនៃភាគីទាំងពីររួចប្រគល់ជូនភាគីនីមួយៗ នូវច្បាប់កិច្ចព្រមព្រៀងជាភាសាខ្មែរមួយច្បាប់ និងជាភាសាអង់គ្លេសមួយច្បាប់ ។ ក្នុងករណីមានការបកប្រែមិនស្របគ្នា ភាសាខ្មែរត្រូវបានយកជាផ្លូវការ។

**ប្រការ ១៣.** កិច្ចព្រមព្រៀងគ្នានេះ នឹងចូលជាធរមាន ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ហើយនិងបន្តមានប្រសិទ្ធភាពដល់បញ្ចប់គម្រោង សំរាប់រយៈពេលបីឆ្នាំគឺឆ្នាំ២០១៥ រហូតដល់ ឆ្នាំ២០១៨។

រាជធានីភ្នំពេញថ្ងៃទី...28...ខែ...05.....ឆ្នាំ ២០១៥

**ភាគ ក**

**តំណាងគណៈកម្មាធិការជាតិ**

**ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

ហត្ថលេខា

..............................................................

ឈ្មោះ **លោកជំទាវ ជូ ប៊ុនអេង**

តួនាទី៖ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

**ភាគ ខ**

**តំណាងអង្គការ ដែនដីមនុស្ស**

**ហូឡង់-ប្រចាំកម្ពុជា**

ហត្ថលេខា

..............................................................

ឈ្មោះ **លោក សួន សុភាព**

តួនាទី៖ អ្នកគ្រប់គ្រងប្រចាំប្រទេស